**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យហែរស្លឹកនៅព្រះសហគមន៍ចំប៉ា**
**ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨**

*ខ្លួនដាក់ខ្លួនដោយបម្រើដូចព្រះយេស៊ូ*

អត្ថបទទី១៖ អស ៥០,៤-៧
អត្ថបទទី២៖ ភីល ២,៦-១១
ដំណឹងល្អ៖ មក ១៤,១-១៥,៤៧

បងប្អូនជាទីស្រឡាញ់!

យើងបានស្តាប់ និងឃើញរបៀបដែលមនុស្សយើង ដែលបានធ្វើបាបព្រះយេស៊ូ ដែលចាប់ព្រះយេស៊ូ ដែលបានស្រែកថាឆ្កាងព្រះយេស៊ូរហូតដល់ព្រះយេស៊ូសោយទិវង្គត។ លិខិតរបស់សន្តប៉ូល ផ្ញើជូនគ្រីស្តបរិស័ទក្រុងភីលីព អំពីព្រះយេស៊ូរងទុក្ខលំបាក **"ព្រះគ្រីស្តយេស៊ូ ដែលមានឋានៈជាព្រះជាម្ចាស់ក៏ពុំមានបំណងទាមទារឲ្យបានស្មើនឹងព្រហជាម្ចាស់ឡើយ។ ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់មកយកឋានៈជាទាសករ ព្រះអង្គបានទៅជាមនុស្សដូចមនុស្សឯទៀតៗ ហើយក៏រស់នៅក្នុងភាពជាមនុស្សធម្មតាដែរ។ ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង។ ហេតុនេះហើយ បានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រោសឲ្យព្រះអង្គមានព្រះនាមដ៏ប្រសើរលើសអ្វីៗទាំងអស់ ដើម្បីឲ្យអ្វីៗទាំងអស់ ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ទាំងនៅក្រោមដី នាំគ្នាក្រាបថ្វាយបង្គំគោរពព្រះនាមព្រះយេស៊ូ និងឲ្យមនុស្សគ្រប់ភាសាប្រកាសឡើងថាព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា"។**

នៅពេលយើងស្តាប់ព្រះបន្ទូលនេះ នៅពេលយើងនឹកឃើញដំណើរចុងក្រោយនៃជីវិតរបស់ព្រះយេស៊ូ ណែនាំឲ្យក្រុមគ្រីស្តទូតចូលនៅក្នុងបុណ្យចម្លង ណែនាំឲ្យក្រុមគ្រីស្តទូតបានទទួលនំប៉័ងដែលជាព្រះកាយ បានទទួលស្រាដែលជាព្រះលោហិតរបស់ព្រះគ្រីស្ត បានឃើញលោកយូដាដែលណែនាំឲ្យក្រុមបូជាចារ្យនិងក្រុមធម្មាចារ្យ ចាប់ព្រះយេស៊ូជាមួយទាហានរ៉ូម៉ាំង។ នៅពេលដែលយើងឃើញ របៀបគេកាត់ក្តីព្រះយេស៊ូយ៉ាងព្រៃផ្សៃដោយសារព្រះយេស៊ូអត់ធ្វើអីខុស ព្រះយេស៊ូបានណែនាំអ្វីខុសបានជាគេចាប់ព្រះយេស៊ូ និងមើលងាយព្រះយេស៊ូដល់កម្រិតនេះ? ប្រសិនបើយើងមើលមួយភ្លែតជីវិតរបស់ព្រះយេស៊ូធ្វើអ្វី? នៅក្នុងបីឆ្នាំដែលព្រះយេស៊ូបានប្រកាសដំណឹងល្អ ព្រះយេស៊ូបានដើរពីភូមិមួយទៅភូមិមួយដើម្បីនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ណែនាំឲ្យអ្នកក្រីក្រមានសេ

ចក្តីសង្ឃឹម ណែនាំឲ្យអ្នកជំងឺជាសះស្បើយ ណែនាំឲ្យជនពិការដើរបាន ណែនាំឲ្យអ្នកជាប់ឃុំឃាំងមានសេរីភាព ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកណាក៏មើលឃើញព្រះយេស៊ូដែរ។ ជាមូលហេតុព្រះយេស៊ូបានសួរគេនៅពេលដែលគេចាប់ព្រះអង្គ "**ជារៀងរាល់ថ្ងៃខ្ញុំនៅធម្មាសាលាអត់ដែលចាប់ខ្ញុំទេ**"។ ប៉ុន្តែនៅថ្ងៃហ្នឹង គេបានសម្រេចចិត្តគេចាប់ព្រះយេស៊ូ ដោយសារព្រះយេស៊ូរំខានចិត្តលោភលន់របស់គេ រំខានអំណាចដែលគេចង់មាន ដោយសារគេឃើញព្រះយេស៊ូណែនាំមហាជនឲ្យដើរតាម ព្រះយេស៊ូណែនាំឲ្យមនុស្សមួយចំនួនទៅជាលែងចូលនៅក្នុងសាសនាយូដាហ្នឹង និងជាពិសេសដោយសារគេឮព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំជាព្រះជាម្ចាស់ ខ្ញុំមកពីព្រះជាម្ចាស់ ខ្ញុំមានអំណាចដែលមកពីព្រះជាម្ចាស់ គ្រប់កិច្ចការដែលខ្ញុំធ្វើក្នុងព្រះនាមព្រះបិតារបស់ខ្ញុំ**"។ ហេតុដូច្នេះ គេមិនចង់ទទួលទេដោយសារគេមើលដោយភ្នែករបស់មនុស្សលោក គេមើលដោយភ្នែករបស់លោកកីយ៍ និងគេអត់មានភ្នែកនៃជំនឿដើម្បីទទួលស្គាល់ដូចលោកសិលាថា "**នេះព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលយាងមកដើម្បីណែនាំឲ្យមនុស្សមានជីវិតអស់កល្បជានិច្ច**"។ រហូតដល់គេកាត់ក្តីព្រះយេស៊ូ ប៉ុន្តែលោកពីឡាត គាត់ដឹងថាព្រះយេស៊ូជាមនុស្សសុចរិត គាត់ដឹងថាព្រះយេស៊ូណែនាំឲ្យស្គាល់សេចក្តីពិត។ លោកពីឡាតគាត់មិនមែនជាអ្នកកាន់សាសនាយូដា ទេគាត់ជាតំណាងនៃរដ្ឋអំណាចរ៉ូម៉ាំង គាត់ជឿលើអាទិទេពយ៉ាងច្រើន ប៉ុន្តែគាត់ដឹងព្រះយេស៊ូជាមនុស្សប្លែក ព្រះយេស៊ូមិនមែនជាមនុស្សម្នាក់ដែលបានធ្វើអំពើបាប ដែលត្រូវការជាប់ទោសធ្ងន់ដូចទាសករ ដូចជាឃាតករដូចយើងបានឃើញបាណាបាសជាដើម។ ដូច្នេះលោកពីឡាត គាត់សួរទៅមហាជន តើឲ្យគាត់ធ្វើអ្វីជាមួយលោកយេស៊ូ? មហាជនឆ្លើយថា **ឆ្កាងទៅៗ** ថ្ងៃនោះមហាជននិយាយទាំងអស់ **ឆ្កាងទៅៗ** និងលោកពីឡាតធ្វើតាមមហាជន ដើម្បីរួចខ្លួនដែរ ក្រោយមកយើងឃើញរបៀបដែលគេវាយព្រះយេស៊ូថែមទៀត និងរបៀបដែលណែនាំឲ្យព្រះយេស៊ូពិបាក របៀបដែលគេមើលងាយព្រះយេស៊ូ របៀបដែលគេស្តោះទឹកមាត់លើព្រះយេស៊ូទៀត រហូតដល់ព្រះយេស៊ូបានស្រែកយ៉ាងខ្លាំង "**ឱព្រះបិតាអើយ! ឱព្រះបិតាអើយ! មូលហេតុអ្វីបានលះបង់ចោលទូលបង្គំ?**" និងព្រះយេស៊ូសោយទិវង្គត។ ព្រះយេស៊ូសោយទិវង្គត នៅថ្ងៃនេះដែលយើងបានប្រារព្ធព្រះយេស៊ូដែលជាព្រះរាជវង្សព្រះបាទដាវីឌ នៅពេលដែលយើងហែស្លឹកអម្បាញ់មិញ ជាថ្ងៃដែលព្រះសហគមន៍របស់យើងក្នុងពិភពលោកទាំងមូល យើងគោរពទិវាយុវជន ដែលសម្តេចប៉ាបយ៉ូហានប៉ូលទីពីរ បានបង្កើតទិវាយុវជននៅក្នុងពិភពលោក ជារៀងរាល់ឆ្នាំនៅថ្ងៃអាទិត្យបុណ្យហែស្លឹក មានយុវជនមកជួបជុំគ្នា

នៅក្រុងរ៉ូម និងថ្ងៃនេះយើងមានយុវជនមួយចំនួនយ៉ាងធំ ដែលជួបជុំគ្នានៅទីក្រុងរ៉ូម ដែលមកពីគ្រប់ទ្វីបទាំងអស់។ យើងមានយុវជនឡាវម្នាក់ ដែលជាតំណាងឲ្យព្រះសហាគមន៍ឡាវ-កម្ពុជា ដើម្បីរួមជាមួយសម្តេចប៉ាបជួបជុំគ្នា ដើម្បីរៀបចំទិវាយុវជនពិភពលោក ដែលនឹងកើតឡើងនៅប្រទេសដាណាម៉ាក ឆ្នាំក្រោយ។ ប៉ុន្តែថ្ងៃនេះ យុវជនយុវនារីជួបជុំគ្នាជាមួយសម្តេចប៉ាប ដើម្បីគិតអំពីជីវិតផ្ទាល់ គិតអំពីការត្រាស់ហៅ គិតអំពីរបៀបដែលយើងជាយុវជន យុវនារី យើងត្រូវតែបន្តប្រកាសដំណឹងល្អ។

នៅថ្ងៃនេះយើងមើលឃើញ ជាពិសេសនៅក្នុងអត្ថបទដំណឹងល្អដែលយើងអានអម្បាញ់មិញ យើងរកឃើញអំពីអត្ថន័យនៃការរងទុក្ខលំបាករបស់ព្រះយេស៊ូ អត្ថន័យដែលព្រះយេស៊ូបានសោយទិវង្គត ដើម្បីដឹកនាំជីវិតរបស់យើង។

**ទីមួយ គឺព្រះយេស៊ូដែលសុខចិត្តដាក់ខ្លួន។** យើងបានស្តាប់អម្បាញ់មិញ ព្រះយេស៊ូដែលមានឋានៈដូចព្រះជាម្ចាស់ មិនចង់ស្មើ មិនសុំឲ្យមានសិរីរុងរឿងដូចព្រះជាម្ចាស់ទេ។ ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់ មកយកឋានៈជាទាសករ ព្រះយេស៊ូធ្វើជាអ្នកបម្រើ នេះជាចំណុចទីមួយសម្រាប់យើងថ្ងៃនេះ។ នៅថ្ងៃព្រហស្បត្តិ៍យើងឃើញ មុនព្រះយេស៊ូបានឲ្យនំប៉័ងទៅជាព្រះកាយ ឲ្យស្រាទៅជាព្រះលោហិត មានន័យថាបូជាជីវិតដើម្បីយើង ព្រះយេស៊ូបានលាងជើង ព្រះយេស៊ូបានដាក់ខ្លួន។ នៅពេលព្រះយេស៊ូយាងចូលទៅក្រុងយេរូសាឡឹម ព្រះយេស៊ូមិនអង្គុយនៅលើបល្ល័ងធ្វើដោយមាស ធ្វើដោយឈើថ្លៃៗ ព្រះយេស៊ូគ្មានកងទ័ពដើម្បីថែរក្សាការពារព្រះអង្គ។ ព្រះយេស៊ូមានតែសត្វលាមួយ មានក្រុមគ្រីស្តទូតមួយចំនួន មានប្រជាជនធម្មតាដែលកោតសរសើរព្រះអង្គ។ ព្រះយេស៊ូជាព្រះមហាក្សត្រ ដែលដាក់ខ្លួនដើម្បីធ្វើជាអ្នកបម្រើ ព្រះយេស៊ូជាព្រះជាម្ចាស់ ប៉ុន្តែព្រះយេស៊ូដាក់ខ្លួនដើម្បីបម្រើយើង និងដើម្បីណែនាំឲ្យយើងធ្វើជាអ្នកបម្រើ។ ដូច្នេះ នៅក្នុងអាទិត្យដ៏ពិសិដ្ឋនេះ ឲ្យយើងបើកភ្នែក ឲ្យយើងគិតដល់ជីវិតរបស់យើង យើងជាគ្រីស្តបរិស័ទ មានន័យថាយើងជាសាវ័ករបស់ព្រះយេស៊ូ យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។ យើងធ្វើដូចម្តេចដើម្បីបម្រើបងប្អូនឯទៀតៗយ៉ាងពិតប្រាកដ ដោយសុខចិត្តដាក់ខ្លួន មិនទៅរកសិរីរុងរឿងតាមលោកកីយ៍ មនុស្សយើង យើងចង់ឲ្យគេកោតសរសើរ យើងចង់ឲ្យគេនិយាយពីស្នាដៃរបស់យើងអស្ចារ្យ។ ប៉ុន្តែនេះជារបៀបរបស់យងមនុស្សលោកកីយ៍ ដូចគេកោតសរសើរព្រះយេស៊ូ ជ័យោព្រះរាជវង្សព្រះបាទដាវីឌ! ប៉ុន្តែក្រោយមកមនុស្សដដែលគេ

ស្រែក "**ឆ្កួតទៅៗ**" ដោយសារគេមើលសិរីរុងរឿងមនុស្សលោកីយ៍។ ប៉ុន្តែនៅពេលនោះព្រះយេស៊ូណែនាំមិនឲ្យយើងមើលព្រះយេស៊ូ ប៉ុន្តែយើងមើលសិរីរុងរឿងរបស់ព្រះបិតា ឲ្យយើងមើលព្រះជាម្ចាស់ដែលស្រឡាញ់យើង ឲ្យយើងមើលព្រះជាម្ចាស់ដែលណែនាំឲ្យយើងមានជីវិតអស់កល្បជានិច្ច។ ថ្ងៃនេះ សូមអញ្ជើញបងប្អូនទាំងអស់គិតពិចារណា តើយើងធ្វើយ៉ាងម៉េច ដើម្បីដាក់ខ្លួនទៅជាអ្នកបម្រើ ដែលចេះស្រឡាញ់បងប្អូនឯទៀតៗយ៉ាងពិតប្រាកដ ដូចព្រះយេស៊ូបានដាក់ខ្លួន ដើម្បីធ្វើតាមព្រះបញ្ញារបស់ព្រះបិតា។

**ទីពីរ** យើងបានស្ដាប់ "**យើងប្រោសប្រទានឲ្យព្រះអង្គ មានព្រះនាមដ៏ប្រសើរ លើសអ្វីៗទាំងអស់**" និងព្រះនាមដ៏ប្រសើររបស់ព្រះអង្គគឺអ្វី? ប្រសិនបើយើងត្រលប់មកវិញដល់ថ្ងៃដែលព្រះយេស៊ូប្រសូត គេដាក់ព្រះនាមយ៉ាងពិសេសទៅព្រះយេស៊ូគឺ "**ព្រះអម្ចាស់នៃសន្តិភាព**" និងនៅថ្ងៃដែលព្រះយេស៊ូប្រសូត យើងឃើញហ្វូងទេវទូតដែលច្រៀងកោតសរសើរព្រះជាម្ចាស់ ដែលយាងមកដើម្បីឲ្យមនុស្សលោកទទួល "**សុខសន្តិភាព**"។ ឈ្មោះ (ព្រះនាម) របស់ព្រះយេស៊ូដ៏ខ្ពង់ខ្ពស់បំផុតគឺនេះ "**ព្រះអម្ចាស់នៃសន្តិភាព**"។ ថ្ងៃនេះយើងគោរពព្រះយេស៊ូដែលយាងមក ដើម្បីណែនាំឲ្យពិភពលោកទទួលសុខសន្តិភាព និងសុខសន្តិភាពនេះ ជាសុខសន្តិភាពដែលចូលជាមួយជីវិតរបស់យើងផ្ទាល់ នៅក្នុងព្រះសហគមន៍របស់យើង នៅក្នុងក្រុមគ្រួសាររបស់យើង។ ជាពិសេសនៅក្នុងឆ្នាំនៃគ្រួសារ ឲ្យយើងនឹកឃើញថាយើងធ្វើយ៉ាងម៉េច ដើម្បីណែនាំសុខសន្តិភាពនៅក្នុងក្រុមគ្រួសាររបស់យើងរៀងៗខ្លួន យើងជាឪពុក យើងជាម្ដាយ យើងជាតា យើងជាយាយ យើងជាកូន យើងធ្វើយ៉ាងម៉េច ដើម្បីឲ្យគ្រួសាររបស់យើង ទៅជាគ្រួសារយ៉ាងសុខសាន្តពិតៗ តាមព្រះយេស៊ូបានណែនាំឲ្យមនុស្សលោកទទួលសេចក្ដីសុខសាន្ត ដោយសារនៅពេលព្រះយេស៊ូប្រកាស អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់មានន័យ ថាទ្រង់ណែនាំឲ្យមនុស្សទាំងអស់ មានសេចក្ដីសុខសាន្តមានសុខសន្តិភាព ដើម្បីរស់នៅក្នុងអំណរសប្បាយនៃព្រះជាម្ចាស់។ សព្វថ្ងៃ យើងបន្តមានសង្គ្រាមនៅក្នុងពិភពលោក យើងបន្តមានភេរវកម្មនៅក្នុងពិភពលោក យើងបន្តមានការឈ្លោះគ្នា និងការស្អប់គ្នា។ ដូច្នេះយើងជាគ្រីស្តបរិស័ទ មុនគេបង្អស់ឲ្យយើងឈរឡើងដើម្បីទៅជាសាក្សីនៃសេចក្ដីសុខសន្តិភាព ឲ្យសុខសន្តិភាពកើតឡើងនៅក្នុងជីវិតយើងផ្ទាល់ នៅក្នុងភូមិរបស់យើង នៅក្នុងគ្រួសាររបស់យើង នៅក្នុងព្រះសហគមន៍របស់យើង នៅក្នុងប្រទេសកម្ពុជាយើង ឲ្យសុខសន្តិភាពទៅជាសញ្ញាសម្គាល់នៃជីវិតរបស់យើងជាគ្រី

ស្តបរិស័ទ។ ពីរ បី ឆ្នាំមុន ខ្ញុំបានបង្កើតហ្វេសប៊ុកមួយ ដែលខ្ញុំចង់ឲ្យយើងផុសរូបភាព រូបថត ពាក្យនិយាយ ពាក្យកំណាព្យ រឿងខ្លីៗ ដើម្បីផ្តល់សក្ខីភាពអំពីសុខសន្តិភាព។ ឲ្យយើងចេះបង្កើតសុខសន្តិភាពហ្នឹង ដោយសារឈ្មោះដ៏ឧត្តមបំផុតរបស់ព្រះយេស៊ូ ឈ្មោះយ៉ាងខ្ពស់បំផុតរបស់ព្រះយេស៊ូគឺ "**សុខសន្តិភាព សេចក្តីសុខសាន្ត**"។ នៅពេលព្រះយេស៊ូបានបង្ហាញខ្លួន នៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះបន្ទូលទីមួយដែលព្រះយេស៊ូមានដល់ក្រុមគ្រីស្តទូត នៅពេលដែលព្រះយេស៊ូបង្ហាញខ្លួនប៉ុន្មានដង គឺព្រះអង្គមានព្រះបន្ទូលតែមួយ "**សូមសេចក្តីសុខសាន្តគង់នៅជាមួយបងប្អូន**"។ នៅពេលលោកអភិបាលចាប់ផ្តើមថ្វាយអភិបូជា លោកអភិបាលនិយាយថា "សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់ គង់ជាមួយបងប្អូន"។ សេចក្តីសុខសាន្តមកពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ណែនាំឲ្យនៅក្នុងជីវិតយើង យើងមានកម្លាំងដើម្បីធ្វើទូតនៃសុខសន្តិភាព។

**ទីបី** យើងបានស្តាប់អម្បាញ់មិញ គឺឈ្មោះហ្នឹង! ដើម្បីឲ្យអ្វីៗទាំងអស់ ទាំងនៅលើមេឃ ទាំងនៅលើផែនដី ទាំងនៅឋានក្រោមមានន័យថានៅឋាននរក នាំគ្នាក្រាបថ្វាយបង្គំគោរពព្រះនាមព្រះយេស៊ូ និងឲ្យមនុស្សគ្រប់ភាសាប្រកាសឡើងថា ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា។ ហេតុនេះហើយ ព្រះបន្ទូលរបស់ព្រះយេស៊ូ សោយទិវង្គតរបស់ព្រះយេស៊ូ ជប់លៀងចុងក្រោយរបស់ព្រះយេស៊ូ ដែលកើតឡើងនៅទីក្រុងយេរូសាឡឹម ដែលមានសាក្សីប៉ុន្មាននាក់ ក្រុមគ្រីស្តទូត ស្ត្រីៗមួយចំនួន ព្រះនាងម៉ារី មហាជនមួយចំនួនដែលនៅទីនោះ នៅ២០០០ឆ្នាំមុន ព្រះបន្ទូលរបស់ព្រះយេស៊ូ សោយទិវង្គតរបស់ព្រះយេស៊ូ ណែនាំឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ សម្រាប់មនុស្សលោក លែងទៅជាសម្រាប់មនុស្សប៉ុន្មាននាក់នៅក្រុងយេរូសាឡឹម លែងទៅជាសម្រាប់ប៉ុន្មាននាក់ដែលបានធ្វើជាសាក្សី២០០០ឆ្នាំមុន។ សិរីរុងរឿងរបស់ព្រះគ្រីស្តសម្រាប់មនុស្សទាំងអស់ យើងប្រកាសដំណឹងល្អរហូតដល់ដាច់ស្រយាលនៃផែនដី។ ព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូ គឺនិយាយឲ្យគ្រីស្តទូត ឥលូវនេះសូមទៅប្រកាសដំណឹងល្អដោយធ្វើពិធីជ្រមុជទឹក ដោយព្រះនាម ព្រះបិតា ព្រះបុត្រ ព្រះវិញ្ញាណដ៏វិសុទ្ធរហូតដល់ដាច់ស្រយាលនៃផែនដី។ ជាមូលហេតុថ្ងៃនេះ យើងអង្គុយនៅវិហារ យើងជាគ្រីស្តបរិស័ទដែលគោរពព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូតែមួយគត់។ នៅក្នុងពិភពលោកទាំងមូល យើងមានគ្រីស្តបរិស័ទដូចគ្នាដែលកំពុងអង្គុយ ថ្ងៃនេះមានមហា

ជនជាមួយយុវជនមកពីគ្រប់ទ្វីប ដែលកំពុងស្តាប់ធម្មទេសនារបស់សម្តេចប៉ាប និងអធិដ្ឋានជាមួយសម្តេចប៉ាប និងនៅគ្រប់ព្រះវិហារក្នុងពិភពលោក ថ្ងៃនេះយើងមានគ្រីស្តបរិស័ទដែលកំពុងកាន់ស្លឹក ដែលកំពុងច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះបាទដាវីឌ និងនៅគ្រប់ព្រះវិហារយើងកំពុងអធិដ្ឋាន និងថ្វាយបង្គំដល់ព្រះយេស៊ូ ដែលសោយទិវង្គតដោយសារ "**ព្រះនាមរបស់ព្រះជាម្ចាស់ ទៅឲ្យមនុស្សគ្រប់ភាសាប្រកាសឡើងថា ព្រះយេស៊ូជាព្រះអម្ចាស់**"។ សាសនារបស់យើង ព្រះយេស៊ូរបស់យើង មិនមែនសម្រាប់តែក្រុមតូចមួយ នៅប្រទេសអ៊ីស្រាអែល ប៉ុន្តែសម្រាប់ពិភពលោកទាំងមូល និងសម្រាប់មនុស្សទាំងអស់។ ហេតុនេះយើងស្តាប់ម្តងទៀត សម្រាប់អ្វីៗទាំងអស់ ទាំងនៅលើមេឃ ទាំងនៅលើផែនដី ទាំងនៅក្រោមដី។ ប៉ុន្តែយើងដឹងថា សិរីរុងរឿងរបស់ព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ យើងលែងគិតអំពីសញ្ជាតិ យើងលែងគិតអំពីភាសា យើងលែងគិតអំពីឋានៈ អំពីវណ្ណៈ យើងជាអ្នកក្រីក្រក៏ដោយ យើងជាអ្នកមានក៏ដោយ យើងជាមនុស្សដែលពោរពេញទៅដោយអំពើបាបក៏ដោយ យើងជាមនុស្សសុចរិតក៏ដោយ យើងជាមនុស្សទុច្ចរិតក៏ដោយ យើងជាជនជាតិណាក៏ដោយ ព្រះបន្ទូលរបស់ព្រះយេស៊ូសម្រាប់យើង ដើម្បីឲ្យយើងទទួលជីវិតថ្មី ដើម្បីឲ្យយើងកសាងសុខសន្តិភាព និងដើម្បីឲ្យយើងកោតសរសើរព្រះនាមរបស់ព្រះអង្គដោយយកចិត្តទុកដាក់ ដាក់ខ្លួនធ្វើជាអ្នកបម្រើ។

ដូច្នេះបងប្អូនជាទីស្រឡាញ់ នៅថ្ងៃនេះយើងចូលនៅក្នុងអាទិត្យពិសិដ្ឋ ដោយត្រៀមខ្លួនដាក់ខ្លួនដោយបម្រើ ដូចព្រះយេស៊ូបានបម្រើ។ ត្រៀមខ្លួនឲ្យទៅជាទូតនៃសុខសន្តិភាពនៅក្នុងគ្រួសារយើង ដូចព្រះយេស៊ូបានណែនាំឲ្យពិភពលោកទទួលសុខសន្តិភាព និងយើងទៅជាគ្រីស្តទូត ដើម្បីប្រកាសដល់មនុស្សទាំងអស់ អ្នកក្រីក្រក្តី អ្នកមានក្តី ជីវិតតរបស់យើងមានតម្លៃ និងរកឃើញអត្ថន័យ លុះត្រាតែយើងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយព្រះជាម្ចាស់ ដែលជាជីវិត ដែលជាផ្លូវ ដែលជាសេចក្តីពិត។ អាម៉ែន។